## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ៖ ៣៩២ អ.ក
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២
ជំនុំជម្រះលេខ៖ ៦៦៩ ជ.វ
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ: ៨៤ (ប)
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល
**នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ដោយមានសមាសភាព៖**

*ក្រុមប្រឹក្សាជំនុំជម្រះ*

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

*តំណាងអយ្យការ*

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

*ក្រឡាបញ្ជីសវនាការ*

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩២ អ.ក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ដែលមាន៖**

-ជនជាប់ចោទឈ្មោះ [redacted] ហៀក ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងដែក កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តត្បូងឃ្មុំ និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សេងហៀវ (រស់) ម្ដាយឈ្មោះ [redacted] សុផល (រស់) នៅលីវ ទោសពីមុនគ្មាន។

**(ឃាត់ខ្លួនថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ និងឃុំខ្លួនតាមដីកាបង្គាប់លេខ: ១០៦១ ដក.បឃខ "វ"/២២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល)។**

-ជាប់ចោទពីបទ: **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅម្ដុំផ្លូវលំ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ ,ទី៤ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-បានឃើញ របាយការណ៍លេខ: ១០៣ របកចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលសង្កាត់ព្រែកហូរ នៃស្នងការនគរបាលខេត្តកណ្ដាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៥៤៩ ដក.សព/២២ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។



Scanned with CamScanner

-បានឃើញ ដីកាដំណោះស្រាយ៖៦០៨ ដកដស/២២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ មានជនជាប់ចោទឈ្មោះ ហឹម ហៀក បានទៅទិញ ថ្នាំញៀននៅម្តុំផ្លូវលំ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ពីក្មេងប្រុស អាយុប្រហែលដប់ឆ្នាំជាង សម្បុរខ្មៅ មាឌស្គម រាងទាប ចំនួន១កញ្ចប់ តម្លៃ ១៥,០០០ (មួយម៉ឺនប្រាំពាន់រៀល) បន្ទាប់ពីទិញរួចជនជាប់ចោទឈ្មោះ ហឹម ហៀង បានជិះម៉ូតូរ៉ឺម៉កចេញមកក៏បានជ្រុលទៅប៉ះម៉ូតូរបស់គេ ហើយជនជាប់ចោទក៏បានជិះរត់ ហើយស្របពេលនោះ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកហូរបានចេញល្បាតក៏បានធ្វើការឃាត់ខ្លួនជនជាប់ចោទខាងលើ និងបានឆែកឆេររកឃើញគ្រឿងញៀនចំនួន ១កញ្ចប់ដែលជនជាប់ចោទបានរក្សាទុកក្នុងហោប៉ៅខោប៊ីយខាងក្រោយផ្នែកខាងឆ្វេង រួចប៉ុស្តិ៍នគរបាលរដ្ឋបាលព្រែកហូរបានបញ្ជូនជនជាប់ចោទ រួមទាំងវត្ថុតាងទៅអធិការដ្ឋាននគរបាលក្រុងតាខ្មៅ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីតែម្តង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ហៀក បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ សមត្ថកិច្ចដកហូតថ្នាំញៀនចំនួន ១កញ្ចប់តូចដែលខ្លួនទិញពីក្មេងប្រុសម្នាក់ម្តុំព្រែកហូរ ក្នុងតម្លៃ ១៥០០០រៀល ជាប្រភេទម៉ាទឹកកក។ ខ្លួនទៅទិញគ្រឿងញៀនម្នាក់ឯង ដោយជិះម៉ូតូម៉ាកសង់ការ៉េរបស់បងខ្លួន។ ពេលទិញបានហើយ ក៏ជិះត្រឡប់មកវិញ បានប្រហែល ៥០០ ម៉ែត្រ សមត្ថកិច្ចក៏ឃាត់ខ្លួន ហើយដកហូតថ្នាំញៀន ១កញ្ចប់ និងម៉ូតូចំនួន ១គ្រឿង។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនបាន ៣ខែហើយ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] ហៀក បានសារភាពថា ថ្ងៃកើតហេតុ បានទិញគ្រឿងញៀនចំនួន ១កញ្ចប់ ក្នុងតម្លៃ ១៥០០០រៀល ត្រូវសមត្ថកិច្ចឃាត់ខ្លួនដកហូត គ្រឿងញៀនចំនួន ១កញ្ចប់ ទម្ងន់ ០,១៣ក្រាម ជាប្រភេទមេតំហ្វេតាមីន។ តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ទុកដដែល ជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ កូនក្តីរបស់ខ្លួនបានសារភាពនូវទោសកំហុស ហើយគ្រឿងញៀនចំនួន ១កញ្ចប់តូចនោះទិញមកដើម្បីប្រើប្រាស់។ ពេលទិញបានហើយយកមកដាក់នៅកន្លែងធ្វើការ។ ជនជាប់ចោទទើបតែប្រើប្រាស់គ្រឿងញៀនបានរយៈពេល ៣ខែ។ សំណូមពរលើកលែងបទចោទពីបទ: រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ឬកែមកជាបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** និងសំណូមពរសម្រាលទោសលើកូនក្តីរបស់ខ្លួន។

+សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ សំណូមពរបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់ដំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១.តុលាការទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ដែលមានជនជាប់ចោទឈ្មោះ [redacted] ហៀក ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទ៖ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមដីកាដំណោះស្រាយលេខ៖ ៦០៨/២២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទយោងតាមមាត្រា ២៨៩, មាត្រា ២៩១ និងមាត្រា ៣៤៨ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

២.ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ,របាយការណ៍របស់សមត្ថកិច្ច ព្រមទាំងភស្តុតាង ឃើញថា នៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] ហៀក បានទិញគ្រឿងញៀនពីក្មេងប្រុសម្នាក់នៅម្តុំព្រែកហូរចំនួន ១កញ្ចប់ ក្នុងតម្លៃ ១៥០០០រៀល ដើម្បីទុកប្រើប្រាស់ ដោយជនជាប់ចោទចេះប្រើប្រាស់គ្រឿងញៀន ៣ខែមកហើយ។ ពេលទិញបានហើយជនជាប់ចោទបានធ្វើដំណើរត្រឡប់មកវិញ បានប្រហែល ៥០០ម៉ែត្រ សមត្ថកិច្ចបានហៅឆែកឆេរដកហូតគ្រឿងញៀន ហើយបានធ្វើតេស្តទឹកនោម ឃើញមានសារធាតុញៀន និងឃាត់ខ្លួន។ អំពើរបស់ជនជាប់ចោទ គឺជាអង្គហេតុត្រូវនឹងធាតុផ្សំបទល្មើស **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ ,ទី៤ និងមាត្រា ៤៥ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

៣.តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ របស់ប៉ុស្តិ៍នគរបាលព្រែកហូរ បានដកហូតគ្រឿងញៀនពីជនជាប់ចោទចំនួន ១កញ្ចប់។ រីឯកំណត់ហេតុស្តីពីការពិនិត្យធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ បានថ្លឹងគ្រឿងញៀនមានទម្ងន់ ០,១៣ក្រាម ជាប្រភេទមេតំហ្វេតាមីន ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

៤.ជនជាប់ចោទឈ្មោះ [redacted] ហៀក មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវបទព្រហ្មទណ្ឌនូវទង្វើររបស់ខ្លួន។

៥.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ហៀក ជាប់ទោទពីបទៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៦.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ ស្នើសុំលើកលែងពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ឬកែមកជាបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤៥ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** វិញលើជនជាប់ចោទ នោះគឺមិនត្រឹមត្រូវទេ អំពើរបស់ជនជាប់ចោទ តុលាការបានលើកជាសំអាងពីខាងលើរួចមកហើយ មិនចាំបាច់លើកសំអាងដដែលនេះមកបញ្ជាក់ទៀតឡើយ។ រីឯការស្នើសុំសម្រាលទោសលើជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណា។

៧.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហៀក ភេទប្រុស អាយុ ១៧ ឆ្នាំ ពីបទ៖ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅម្តុំផ្លូវលំ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ ,ទី៤ និងមាត្រា ៤៥ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។



Scanned with CamScanner

៨.អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៀក បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។ ក៏ប៉ុន្តែជនជាប់ចោទជាអនីតិជន ដូចច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ គុណាការនឹងពិនិត្យពិចារណា។

៩.វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល រួមមាន៖ ថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ០១កញ្ចប់ មានទម្ងន់ ០,១៣ក្រាម ជាវត្ថុខុសច្បាប់ គប្បីរឹបអូស។ រីឯទូរស័ព្ទមួយគ្រឿងម៉ាក Huawei ពណ៌ខ្មៅ(មិនប្រក្រតី) និងម៉ូតូចំនួនមួយម៉ាកសង់ការ៉េ គ្មានស្លាកលេខ(មិនប្រក្រតី) ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន គប្បីប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

**ហេតុដូច្នេះសម្រេច**

១/-ផ្តន្ទាទោសឈ្មោះ [redacted] ហៀក ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ក្នុងរយៈពេល ១(មួយ)ឆ្នាំ ពីបទ៖ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅម្តុំផ្លូវលំ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ ,ទី៤ ,មាត្រា ៤៥ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

២/-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល មាន៖

ក/រឹបអូសថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ០១កញ្ចប់ មានទម្ងន់ ០,១៣ក្រាម។

ខ/ប្រគល់ទូរស័ព្ទមួយគ្រឿងម៉ាក Huawei ពណ៌ខ្មៅ(មិនប្រក្រតី) និងម៉ូតូចំនួនមួយម៉ាកសង់ការ៉េ គ្មានស្លាកលេខ(មិនប្រក្រតី) ឱ្យទៅម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ,ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា និងត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តកណ្តាល ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]



Scanned with CamScanner